# ច្បាប់ការងារសំរាប់អនីតិជន ក្នុងរដ្ឋម៉ាសាជូសេត្ស៍* 2010

## ពេលវេលាធ្វើការស្របច្បាប់សំរាប់អនីតិជន

### អាយុ 14 និង 15 ឆ្នាំ

**ម៉ោងធ្វើការ**

*កំឡុងពេលឆ្នាំសិក្សា:*
- ត្រឹមចន្លោះម៉ោង7 ព្រឹកនិងម៉ោង 7ល្ងាច
- មិននៅក្នុងម៉ោងរៀន

*ក្នុងរដូវក្តៅ*
*(ថ្ងៃទី 1 កក្កដា- ទិវាកម្មករ):*
- ត្រឹមចន្លោះម៉ោង7 ព្រឹកនិងម៉ោង9 យប់

**ចំនួនម៉ោងអតិបរិមា**

*ពេលសាលា**កំពុង**ដំណើរការ:*
- 18 ម៉ោងក្នុងមួយសប្តាហ៍
- 3 ម៉ោងក្នុងមួយថ្ងៃនៅថ្ងៃរៀន
- 8 ម៉ោងក្នុងមួយថ្ងៃនៅថ្ងៃចុងសប្តាហ៍និងថ្ងៃសំរាក
- 6 ថ្ងៃក្នុងមួយសប្តាហ៍

*ក្នុងពេល**វិស្សមកាល**:*
- 40 ម៉ោងក្នុងមួយសប្តាហ៍
- 8 ម៉ោងក្នុងមួយថ្ងៃ
- 6 ថ្ងៃក្នុងមួយសប្តាហ

យុវជន-យុវតីទាំងអស់ក្រោមអាយុ 18ឆ្នាំត្រូវតែ សុំ**លិខិតអនុញ្ញាតធ្វើការ**ពីសាលាតំបន់ដែលគេរស់នៅ ឬក៏សាលាដែលគេទៅរៀន។ សំរាប់ព័ត៌ មានបន្ថែមទស្សនា គេហទំព័រអង្គភាពដើម្បីសុវត្ថិភាពកន្លែងធ្វើការ:
www.mass.gov/dos/youth

### អាយុ 16 និង 17 ឆ្នាំ

**ម៉ោងធ្វើការ**

*រយៈពេល**ពេញ**មួយឆ្នាំ:*
- ត្រឹមចន្លោះម៉ោង6 ព្រឹកនិងម៉ោង 10 យប់ នៅយប់មុនថ្ងៃរៀនធម្មតា
- បើហាងឈប់បំរើអតិថិជននៅម៉ោង10 យប់ អនីតិជនអាចធ្វើការដល់ម៉ោង 10:15 យប់
- ត្រឹមចន្លោះម៉ោង6 ព្រឹកនិងម៉ោង 11:30 យប់ នៅយប់មុនថ្ងៃមិនរៀនធម្មតា លើក លែង តែនៅក្នុងហាងនិងកន្លែងប្រណាំងសេះ រហូតដល់ម៉ោង 12 យប់

**ចំនួនម៉ោងអតិបរិមា**

*រយៈពេល**ពេញ**មួយឆ្នាំ:*
- 48 ម៉ោងក្នុងមួយសប្តាហ៍
- 9 ម៉ោងក្នុងមួយថ្ងៃ
- 6 ថ្ងៃក្នុងមួយសប្តាហ៍

បន្ទាប់ពីម៉ោង៨យប់ អនីតិជនទាំងអស់ត្រូវតែមានមនុស្សចាស់នៅមើល ដែលមានវត្តមាន នៅកន្លែងធ្វើការនោះ ហើយដែលអាចមានវិធីគ្រប់គ្រាន់ទៅដល់កន្លែង។
(លើកលែងតែអនីតិជនដែលធ្វើការនៅតាមតូបលក់ឥវ៉ាន់នៅទីប្រជុំជនក្នុងហាងទំនិញធំៗ)

## កិច្ចការត្រូវគេហាមសំរាប់អនីតិជន

### បុគ្គលក្រោមអាយុ 16 ឆ្នាំ មិនអាច:

- បើកបរ សំអាត ឬជួសជុលម៉ាស៊ីនយន្ត(លើកលែងគ្រឿងម៉ាស៊ីននៅក្នុងការិយាល័យ ឬក៏ម៉ាស៊ីននៅកន្លែងលក់ដូរ ម៉ាស៊ីនសំអាត ឬកិច្ចការក្នុងផ្ទះបាយដែលគេមិនហាមប្រាម)
- ធ្វើម្ហូប(លើកលែងប្រើចង្ក្រានអគ្គីសនីឬក៏ចង្ក្រានអាំងហ្គាសដែលពុំមានអណ្តាតភ្លើងចេញមកក្រៅ)
- ប្រើប្រាស់ឆ្នាំងបំពង ចង្ក្រានអាំង ចង្ក្រានអាំងNIECO ឬក៏ចង្ក្រានដែលប្រើសម្ពាធដទៃទៀត
- ប្រើប្រាស់ សំអាតឬជួសជុលម៉ាស៊ីនឈូសសាច់ ម៉ាស៊ីនកិន ចិញ្ច្រាំ ផលិត ប្រដាប់កាត់ឬលាយ
- ធ្វើកិច្ចការអ្វីទាក់ទងនិងការដុត
- ប្រើប្រាស់ចង្ក្រានម៉ៃក្រូវ៉េវ(លើកលែងតែកំដៅម្ហូបនៅក្នុងម៉ៃក្រូវ៉េវដែលមានកំដៅអតិបរិមាត្រឹម កំរិត 140 ហ្វារិនហៃ)
- សំអាតតួចង្ក្រានដែលក្តៅជាង 100 ហ្វារិនហៃ
- ត្រង ដឹកជញ្ជូន ឬចាក់ប្រេងចំអិន ឬខ្លាញ់ដែលក្តៅជាង 100 ហ្វារិនហៃ
- ធ្វើការក្នុងទូធ្វើឲ្យកក ឬក៏ទូខ្វះសេសាច់
- ធ្វើការក្នុងអាគារគ្រឿងចក្រ ឬមុខរបរនោះ (ឧទាហរណ៍: ក្នុងរោងចក្រ ជាអ្នកផ្គុំឥវ៉ាន់)
- ធ្វើការនៅខាងលើ ឬប្រើជណ្តើរ រន្ទា(ឧបករណ៍គ្រោង) ឬក៏របស់របរប្រហាក់ប្រហែលគ្នា
- ធ្វើការនៅក្នុងជាងរថយន្ត លើកលែងតែបង្ហូរ និងចាក់ប្រេង
- ធ្វើការក្នុងរោងរៀបឥដ្ឋ ឬធ្លារៀបឈើបន្ទះ
- ធ្វើការក្នុងឧទ្យានលេងកំសាន្ត (ឧទាហរណ៍: បន្ទប់លេងបីយា ឬកន្លែងកីឡាបោះប៊ូល)
- ធ្វើការក្នុងហាងកាត់សក់
- ធ្វើការដើរលក់តាមផ្ទះ រួមបញ្ចូលទាំងធ្វើជាអ្នកស៊ីញ៉េឲ្យសញ្ញា(លើកលែងតែនៅជាប់ខាងក្រៅផ្ទាល់នៃហាងរបស់និយោជក)
- ធ្វើការខាងសំណង់ ដឹកជញ្ជូន គមនាគមន៍ ឬក៏សេវាកម្មសាធារណៈនានា(លើកលែងតែធ្វើកិច្ចការផ្នែកក្រដាសស្នាមដែលឆ្ងាយពីគ្រឿងយន្តធ្ងន់ៗ នៅឆ្ងាយពីកន្លែងការងារធ្ងន់នោះ)។
- ធ្វើការក្នុងឃ្លាំង(លើកលែងតែកិច្ចការទាក់ទងក្រដាសស្នាម)
- ជញ្ជូនឥវ៉ាន់ឡើង ឬចុះពីរថយន្តដឹកជញ្ជូន ទូរទេះភ្លើង ឧបករណ៍ដឹកជញ្ជូននានា
- ជិះខាងក្នុង ឬលើរថយន្ត(លើកលែងតែកៅអីអ្នកដំណើរ បើសិនជាពាក់ខ្សែក្រវាត់ជាប់កៅអី)
- ធ្វើការកន្លែងបោកគក់ក្នុងកន្លែងជំនួញទទួលខាងបោកគក់ ឬកន្លែងអ៊ុតសំអាតសំលៀកបំពាក់
- ធ្វើការជាអ្នកនាំពាក្យសាធារណៈ
- ធ្វើការនៅកន្លែងប្រតិបត្តិការផលិតកម្ម(ដូចជាសាច់ ឬត្រី ឬចាប់មាន់ទា ទ្រង់មាន់ទា បំបែកគ្រាប់ផ្លែឈើរឹងៗ ឬក្នុងកន្លែងធ្វើសំបុត្រទំាងជុំៗ ឬសំបុត្ររយ)
- ធ្វើការនៅក្បែរធុងផលិតទឹកក្តៅ ឬរោងម៉ាស៊ីន
- ធ្វើកិច្ចការឧស្សាហកម្មខាងសំណង់ផ្ទះ
- ធ្វើការជាមួយគ្រឿងយន្តអគ្គីសនី ឬគ្រឿងប្រើប្រាស់ក្នុងផ្ទះដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់
- កិច្ចការដែលអគ្គមេធាវីរដ្ឋម៉ាសាជូសេត្ស៍ចាត់ទុកថា អាចបណ្តាលឲ្យគ្រោះថ្នាក់ដល់សុខភាព និងសុខមាលភាពរបស់អនីតិជន
- **កិច្ចការណាក្នុងមុខរបរ ឬកាតព្វកិច្ចណាដែលគេហាមឃាត់សំរាប់បុគ្គលមានអាយុក្រោម 18ឆ្នាំ**

*កិច្ចការជាក់លាក់ណាមួយដែលក្រសួងការងារសហរដ្ឋអាមេរិកគេមិនអនុញ្ញាតអោយធ្វើ។*

**បុគ្គលក្រោមអាយុ 14 ឆ្នាំមិនអាចធ្វើការ!** មានករណីលើកលែងពីរ-បី ដូចជាការមើលកូនក្មេង ធ្វើជាអ្នកដើរដាក់កាសែត នៅលើកសិដ្ឋាន និងនៅកន្លែងកំសាន្ត (ដោយមានការអនុញ្ញាតពិសេស)។

### បុគ្គលក្រោមអាយុ 18 ឆ្នាំ មិនអាច:

- បើកបររថយន្ត រថយន្តលើកឥវ៉ាន់ ឬកិច្ចការដែលជួយរថយន្ត(លើកលែងតែរថយន្តកូនគោលក្នុងកាលៈទេសៈខ្លះ)
- ជិះជាអ្នកដំណើរលើរថយន្តលើកឥវ៉ាន់
- ប្រើប្រាស់ សំអាត ឬជួសជុលម៉ាស៊ីនហាន់សាច់ ម៉ាស៊ីនកិន ឬចិញ្ច្រាំ
- ប្រើប្រាស់ សំអាត ឬជួសជុលម៉ាស៊ីនធ្វើនំ (លើកលែងតែម៉ាស៊ីនសំរាប់ប្រើលើតុខ្លះ និងម៉ាស៊ីនលាយម្សៅភីស្សា)
- កិច្ចការដែលមានកំពស់លើសពី 30 ហ្វីតពីដី ឬទឹក
- ចាត់ចែង បំរើ ឬលក់ភេសជ្ជៈជាតិស្រវឹង
- ប្រើប្រាស់រណារមូល ចង្វាក់ បន្ទះ, ម៉ាស៊ីនកាត់បង្អិលផ្លែ ប្រដាប់ដាប់ឈើ និងម៉ាស៊ីនដែលមានផ្លែសំរាប់ឈូស
- ប្រើប្រាស់ឧបករណ៍សំរាប់ឈើដែលប្រើគ្រឿងម៉ាស៊ីន
- ប្រើប្រាស់ ជួសជុល បើកបរ ឬកិច្ចការណាចេញមកពីម៉ាស៊ីនលើកស្ទូច
- ប្រើប្រាស់ ឬបំពេញម៉ាស៊ីនសំរាប់ចងបាច់ គ្រាក់ទំរត្តូចៗ ឬម៉ាស៊ីនកិនក្រដាស
- ប្រើប្រាស់ម៉ាស៊ីនពត់ដែក ចោះរន្ធ ឬម៉ាស៊ីនកាត់ច្រៀក
- ប្រើប្រាស់ម៉ាស៊ីនខាត់ ឬឧបករណ៍ដុះខាត់
- ប្រើពុម្ពចាក់ឥដ្ឋជុំៗ ឥដ្ឋស្តើង ឬក៏ផលិតផលប្រហាក់ប្រហែលគ្នា
- ប្រើគ្រឿងផ្ទុះផលិតក្នុងរោងចក្រ ឬក្នុងហាងជំនួញ
- ធ្វើការក្នុងរូងដី កន្លែងកំទិច រំលាយចោល ឬការបំបែកកប៉ាល់ចោល
- ធ្វើជាអ្នកបង្ក្រាបអគ្គីភ័យនៅក្នុងព្រៃ អ្នកអភិរក្សរុក្ខាកុំឲ្យភ្លើងឆេះ អ្នកធ្វើការនៅក្នុងផ្លូវគេ ដឹកជញ្ជូនឈើ និងការងារផ្សេងៗ ទាក់ទងរុក្ខជាតិ
- មានមុខរបរកាប់ឈើ រោងអារឈើ ឬជីករ៉ែ
- ធ្វើការកន្លែងសំលាប់សត្វ វេចខ្ចប់ ឬផលិតសាច់សត្វ និងមាន់ទា
- ធ្វើការក្នុងក្រុមហ៊ុនអយស្ម័យយាន
- ធ្វើការខាងដំបូល ឬលើ ឬអំពីដំបូល
- ធ្វើការផ្នែកដុតចំរាញ់លោហៈ ឬក៏នៅក្បែរឡសំរាប់ដុត
- ធ្វើការក្នុងរោងចក្រផលិតជាតិហ្វូសហ្វ័រ ឬឈើគូសដែលមានជាតិហ្វូសហ្វ័រ
- ធ្វើការកន្លែងដែលត្រូវប៉ះពាល់ដោយសារធាតុវិទ្យុសកម្ម
- ធ្វើជាអ្នកបង្ក្រាបអគ្គីភ័យ ឬវិស្វករនៅលើកាណូត
- ធ្វើជាអ្នកសំអាតជាតិប្រេង ឬគ្រឿងយន្តមានចលនាដែលអាចបណ្តាលឲ្យគ្រោះថ្នាក់
- ធ្វើការអ្វីដែលតម្រូវឲ្យមាន ឬប្រើប្រាស់សព្វាវុធ

### ប្រភពនានាសំរាប់ព័ត៌មានបន្ថែមទៀត

បើមានសំណួរពីប្រាក់ឈ្នួល ឬច្បាប់ការងារសំរាប់អនីតិជន:
- ការិយាល័យអគ្គមេធាវីរដ្ឋម៉ាសាជូសេត្ស៍
  អង្គភាពអនុវត្តការងារ និងជំនួញសមរម្យ
  www.ago.state.ma.us - (617) 727-3465
- ក្រសួងការងារសហរដ្ឋអាមេរិក, អង្គភាពប្រាក់ឈ្នួល និងម៉ោងធ្វើការ
  www.dol.gov/esa/whd - (617) 624-6700

បើមានសំណួរពីសំណងកម្មករ:
- គ្រោះថ្នាក់តាមក្រុមហ៊ុននៃរដ្ឋម៉ាសាជូសេត្ស៍
  www.mass.gov/dia - (800) 323-3249 x470

បើមានសំណួរពីសុខភាព និងសុវត្ថិភាព:
- ក្រសួងការងារសហរដ្ឋអាមេរិក
  ស្ថាប័នផ្នែកសុវត្ថិភាពមុខជំនាញ និងសុខភាព
  www.osha.gov
  ការិយាល័យ Andover - (978) 837-4460
  ការិយាល័យ Braintree - (617) 565-6924
  ការិយាល័យ Springfield - (413) 785-0123
- ក្រសួងសុខាភិបាលរដ្ឋម៉ាសាជូសេត្ស៍
  កម្មវិធីតាមសង្កេតមើលសុខភាពតាមកន្លែងធ្វើការ
  កម្មវិធីតាមសង្កេតមើលរបួសនិងការពារយុវជននៅកន្លែងធ្វើការ
  www.mass.gov/dph/teensatwork - (617) 624-5632

*នេះគឺជាប្រជុំច្បាប់សំរាប់អនីតិជនរបស់រដ្ឋ និងសហព័ន្ធ។ ច្បាប់ការពារតឹងតែងបំផុតត្រូវគេបង្ហាញនៅទីនេះ និងអនុវត្តលើនិយោជករបស់អនីតិជនទាំងអស់ក្នុងរដ្ឋម៉ាសាជូសេត្ស៍ រួមបញ្ចូលទាំងញាតិសណ្តានដែលជួលសមាជិកគ្រួសារជំទង់ៗ របស់ខ្លួន។ មានក្រិត្យក្រមបន្ថែមទៀត ហើយការលើកលែងខ្លះដូចជាផ្នែកកសិកម្ម និងសំរាប់សិស្សានុសិស្សចូលរួមក្នុងកម្មវិធីសហប្រតិបត្តិការការសិក្សា។

ប័ណ្ណប្រកាសនេះត្រូវផលិតដោយកម្មវិធីតាមសង្កេតមើលរបួសនិងការពារយុវជននៅកន្លែងធ្វើការនៃក្រសួងសុខាភិបាលរដ្ឋម៉ាសាជូសេត្ស៍ និងការិយាល័យអគ្គមេធាវីរដ្ឋម៉ាសាជូសេត្ស៍ដោយមានការឧបត្ថម្ភពីវិជ្ជាស្ថានជាតិសំរាប់សុវត្ថិភាពនិងសុខភាពកន្លែងការងារ។ សំរាប់ព័ត៌មានបន្ថែមទៀត សូមមេត្តាទូរស័ព្ទទៅ(617) 624-5632 ឬក៏អ៊ីមែលយើងខ្ញុំនៅ teens.atwork@state.ma.us.

[Khmer]